# ធម៌នមស្ការសង្ខេប

បោះពុម្ពផ្សាយជាធម្មទាន

ដោយ

## វត្តខេមររតនារាម

ព.ស. ២៥៦៧ - គ.ស. ២០២៣

# ធម៌នមស្ការសង្ខេប

## វត្តខេមររតនារាម

### បោះពុម្ពផ្សាយជាធម្មទាន

ចំនួន ៥០០ក្បាល

ព.ស. ២៥៦៧ - គ.ស. ២០២៣

# មាតិកាធម៌


អារម្ភកថា ............................................................................ទំព័រ I

ឧទ្ទិសកថា.............................................................................ទំព័រ II

សេចក្ដីថ្លែងអំណរគុណ ..............................................................ទំព័រ III

អភិវាទនកិច្ច ..........................................................................ទំព័រ ០១

បទសរភញ្ញ (សម្រាប់សូត្រគោរពទង់សាសនា) ..................................ទំព័រ ០២

រតនត្តយបូជា (ឥមេ ហិ)............................................................ទំព័រ ០៣

ពុទ្ធរតនប្បណាម (នមោ តស្ស)......................................................ទំព័រ ០៣

ពុទ្ធរតនប្បណាម (ថ្វាយបង្គំព្រះពុទ្ធរតនៈ) .......................................ទំព័រ ០៤

ធម្មរតនប្បណាម (ថ្វាយបង្គំព្រះធម្មរតនៈ) .......................................ទំព័រ ០៧

សង្ឃរតនប្បណាម (ថ្វាយបង្គំព្រះសង្ឃរតនៈ) ....................................ទំព័រ ០៩

បណាមគាថា (យោកប្បកោដី) ......................................................ទំព័រ ១៣

រតនត្តយវន្ទនគាថា (ឥច្ចេវំមច្ចន្ត) ..................................................ទំព័រ ១៥

រតនត្តយាភិបូជាគាថា (វត្ថុតីបុគ្គល) ..............................................ទំព័រ ១៦

នមស្ការបូជនីយវត្ថុជាទីគោរព (វន្ទាមិ ចេតិយំ).................................ទំព័រ ១៧

ពុទ្ធបាទនមស្ការគាថា (វន្ទាមិ ពុទ្ធំ)................................................ទំព័រ ១៨

នមស្ការបែបសង្ខេប (ព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណសង្ខេប).................ទំព័រ ២១

ពាក្យប្ដេជ្ញាកាន់យកត្រៃសរណគមន៍ដរាបដល់និព្វាន ..............................ទំព័រ ២១

ខមាទោសព្រះរតនត្រ័យ (កាយេន វាចា).........................................ទំព័រ ២៣

ផ្សាយមេត្តាចំពោះទិសទាំង១០ (សព្វេ បុរត្ថិមាយ)..............................ទំព័រ ២៥

អនុមោទនារក្ខាយាចនគាថា (អាកាសដ្ឋា).........................................ទំព័រ ២៨

សុមង្គលគាថា (ហោតុ សព្វំ). ......................................................ទំព័រ ៣០

បត្តិទានគាថា (ឥមិនា)..............................................................ទំព័រ ៣០

ខមាបនគាថា (យេ កេចិ ខុទ្ទកា) ..........................................................ទំព័រ ៣១
បត្តិទានគាថា (យំ កិញ្ចិ)...............................................................ទំព័រ ៣២
បត្តិទានគាថា (ប្រែជាពាក្យកាព្យ)........................................................ទំព័រ ៣២
បត្តិទានគាថា (វិទានខ្ញុំធ្វើហើយ) ......................................................ទំព័រ ៣៣
បត្តិទានគាថា (យា ទេវតា)..............................................................ទំព័រ ៣៥
បត្តិទានគាថា (យា ទេវតា បាលី - ប្រែ) ..............................................ទំព័រ ៣៦
តេជៈខ្ញុំសាង ..............................................................................ទំព័រ ៣៨
បារមីសាមសិប ............................................................................ទំព័រ ៣៩
បារមីសាមសិប (បាលី - ប្រែ)...........................................................ទំព័រ ៤១
ភាសិតោវាទ សង្ខេប.......................................................................ទំព័រ ៤៥
បច្ឆិមពុទ្ធវចនៈ ............................................................................ទំព័រ ៥៤
វន្ទាព្រះពុទ្ធ ...............................................................................ទំព័រ ៥៧
សមាទានបញ្ចសីល (សីល៥)..............................................................ទំព័រ ៥៨
សមាទានឧបោសថសីល (សីល៨) ........................................................ទំព័រ ៥៨
ធម្មទេសនាយាចនគាថា.....................................................................ទំព័រ ៥៩
បន្ទីសព្វសាធុការពេលចប់ធម្មទេសនា..................................................ទំព័រ ៦២

# អារម្ភកថា

សៀវភៅ ធម៌នមស្ការសង្ខេបនេះ បានរៀបចំឡើងដោយព្រះសង្ឃ អាចារ្យគណៈកម្មការនៃពុទ្ធិកសមាគមខ្មែរ វត្តខេមររតនារាម ( ហៅវត្តចាស់ ឬវត្ត៤៧ ) នាទីក្រុងសាន់ឌីអេហ្គោ រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក។

សៀវភៅ ធម៌នមស្ការសង្ខេបនេះ បានដកស្រង់ចេញពីសៀវភៅ គហិបដិបត្តិ និងសៀវភៅមួយចំនួនផ្សេងទៀត ជាពិសេសបានស្រង់ចេញពីគេហទំព័រ www.watkhmers.org ដែលជាគេហទំព័ររបស់វត្តខេមររតនារាម ក្នុងគោលបំណងដើម្បីជាវិភាគទានខ្លះៗ ក្នុងការចូលរួមអប់រំ សតិបញ្ញាស្មារតី និងជាពន្លឺដល់ពុទ្ធបរិស័ទទូទៅ ដែលចង់សិក្សារៀនសូត្រ គោរពប្រតិបត្តិពុទ្ធសាសនា ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្លួនផង ដល់ជនទាំងឡាយទៀតផង និងដើម្បីញុំាងពុទ្ធសាសនាឱ្យចម្រើនរុងរឿងគង់វង្សឋិតថេរអស់កាលជាយូរអង្វែងតរៀងទៅ។

# ឧទ្ទិសកថា

ដោយផលានិសង្ស ដែលកើតចេញពីសេចក្ដីជ្រះថ្លាក្នុងការតាក់តែងរៀបចំឱ្យកើតជាសៀវភៅនេះឡើង សូមឧទ្ទិសកុសលផលបុណ្យទាំងអស់នេះ ជូនចំពោះ បុព្វបុរស បុព្វការីជន មាតា បិតា គ្រូឧបជ្ឈាយាចារ្យ ព្រះគ្រូចៅអធិការ លោកអាចារ្យ គណកម្មការ ដូនជី តាជី និងពុទ្ធបរិស័ទទាំងអស់ដែលបានបូជា ពលី ទាំងស្មារតីកម្លាំងកាយចិត្ត ធនធាន លុយកាក់មាសប្រាក់ ក្នុងការរួបរួមសាមគ្គីកសាងពុទ្ធិកសមាគមខ្មែរ វត្តខេមររតនារាមនេះឡើង ជាសាសនសម្បត្តិជាតិខ្មែរ ជាទីកន្លែងសម្រាប់បំពេញនូវសាសនកិច្ច ជាទីកើតឡើងនៃបុណ្យ និងជាកន្លែងអប់រំបណ្ដុះបណ្ដាល សាបព្រោះវប្បធម៌ប្រពៃណីអក្សរសាស្ត្រខ្មែរ ផ្ទេរបន្តដល់កុលបុត្រកុលធីតាបច្ឆិមាជនតាជន សូមបានជាបច្ច័យ បានជាឧបនិស្ស័យរួចផុតចាកទុក្ខទាំងអស់កុំបីអាក់ខានឡើយ។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងអស់គ្នាដែលជាអ្នករៀបរៀងសៀវភៅ ធម៌នមស្ការសង្ខេប នេះឡើង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះពុទ្ធបរិស័ទ ដែលបានជួយជ្រោមជ្រែងក្នុងការរៀបរៀងចងក្រងសៀវភៅនេះ មានដូចជា៖

## <u>ស្រាវជ្រាវឯកសារ និងវាយអក្សរដោយ</u>

**ព្រះភិក្ខុ បទីបាលោ ង៉ែត ឃាង**

ព្រះគ្រូសូត្រឆ្វេង វត្តខេមររតនារាម សហរដ្ឋអាមេរិក

**ព្រះភិក្ខុ ចន្ទធម្មោ សេង រិទ្ធី**

គង់នៅ វត្តខេមររតនារាម សហរដ្ឋអាមេរិក

**លោកបណ្ឌិត ធម្មញាត ផនប្រសិទ្ធី**

លោកអាចារ្យសម្រាប់ វត្តខេមររតនារាម សហរដ្ឋអាមេរិក

## <u>ត្រួតពិនិត្យអក្ខរាវិរុទ្ធដោយ</u>

**លោកបណ្ឌិត ធម្មញាត ផនប្រសិទ្ធី**

លោកអាចារ្យសម្រាប់ វត្តខេមររតនារាម សហរដ្ឋអាមេរិក

**<u>ឧបត្ថម្ភបោះពុម្ពដោយ</u>**

**ព្រះភិក្ខុ បញ្ញាបទីបោ សួន ប្រុស**

ព្រះគ្រូសូត្រស្តាំ វត្តខេមររតនារាម សហរដ្ឋអាមេរិក

**ព្រះភិក្ខុ បទីបាលោ ថៃត ឃាង**

ព្រះគ្រូសូត្រឆ្វេង វត្តខេមររតនារាម សហរដ្ឋអាមេរិក

**ឧបាសក ឡុង ម៉ន**

គណៈកម្មការពុទ្ធិកសមាគមខ្មែរ វត្តខេមររតនារាម សហរដ្ឋអាមេរិក

# **អភិវាទនកិច្ច**

នៅពេលចូលទៅកាន់វត្តណាមួយក្តី ពេលថ្វាយបង្គំលាក្តី ឬរាល់ពេលមុននឹងចាប់ផ្តើមធ្វើកិច្ចនមស្ការព្រះរតនត្រៃក្តី ពេលចប់ពិធីកម្មខាងសាសនាណាមួយក្តី កិច្ចដែលគប្បីធ្វើ គឺការក្រាបចុះថ្វាយបង្គំព្រះរតនត្រៃ ៣ ដង ដោយអង្គុយតាមសម្រួល លើកដៃប្រណម្យអញ្ជលីជាក្រពុំផ្កាឈូកនៅត្រង់ដើមទ្រូង រួចហើយពោលក្នុងចិត្តនូវពាក្យខាងក្រោមនេះ ឬបើនឹងចាប់ផ្តើមនមស្ការព្រះរតនត្រៃច្រើនគ្នា គប្បីពោលព្រមៗ គ្នា ឈប់ត្រង់ចំណុចក្បៀស ។

**អរហំ សម្មាសម្ពុទ្ធោ ភគវា, ពុទ្ធំ ភគវន្តំ អភិវាទេមិ ៕**

*(ក្រាបចុះ១ ដង)*

**ស្វាក្ខាតោ ភគវតា ធម្មោ, ធម្មំ នមស្សាមិ ៕**

*(ក្រាបចុះ១ ដង)*

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ, សង្ឃំ នមាមិ ៕**

*(ក្រាបចុះ១ ដង)*

# បទសរភញ្ញ

(សម្រាប់សូត្រគោរពទង់សាសនា)

សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេព្តា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ។
ចង្អុលឱ្យដើរផ្លូវកណ្តាល មាគ៌ាត្រកាលអាចកម្ចាត់
ទុក្ខភ័យចង្រៃឱ្យខ្ចាយបាត់ អាចកាត់សង្សារទុក្ខបាន ។
សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបុរាណ
ប្រឹងរៀនប្រឹងស្តាប់ចេះចាំបាន កាន់តាមលំអានបានក្តីសុខ។
ឥតមានសុខណាស្មើក្តីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្តីសុខនឹងមានព្រោះធម៌ស្ងប់។
សូមថ្វាយបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរតន៍គួរគោរព ជាម្លប់ត្រជាក់នៃលោកា ។
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធតាងអង្គព្រះសាស្តា
សូមគុណត្រៃរតន៍ជួយខេមរា ឱ្យបានសុខាតរៀងទៅ ៕

ព្រះរាជនិពន្ធ សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ

(ក្រាបថ្វាយបង្គំម្តង)

# រតនត្តយបូជា

**ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិ-បូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀននិងធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ៕

(ក្រាបថ្វាយបង្គំម្តង)

# ពុទ្ធរតនប្បណាម

ថ្វាយបង្គំព្រះពុទ្ធរតនៈ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (សូត្រ៣ចប់)

វីកិរិយានមស្ការ ថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹង

នូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ៕

ថ្វាយបង្គំព្រះពុទ្ធរតនៈ

**យោ សន្និសិន្នោ វរពោធិមូលេ**

**មារំ សសេនំ មហតឹ វិជេយ្យោ**

**សម្ពោធិមាគច្ឆិ អនន្តញាណោ**

**លោកុត្តមោ តំ បណមាមិ ពុទ្ធំ ៕**

ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើន នូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**

**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ៕**

ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ និព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធ

ទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រកប្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។

**ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគនិងវចីបយោគ **សម្មា-សម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា៣ និងវិជ្ជា៨ និងចរណៈ១៥ **សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន **សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា

និងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឱ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ទាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

**នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ដោយអវយវៈដ៏ឧត្តមគឺត្បូង **ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់ **ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ៕

(ក្រាបថ្វាយបង្គំម្តង)

# ធម្មរតនប្បណាម

ថ្វាយបង្គំព្រះធម្មរតនៈ

**អដ្ឋង្គិការិយបថោ ជនានំ**

**មោក្ខប្បវេសាយ ឧជូ ច មគ្គោ**

**ធម្មោ អយំ សន្តិករោ បណីតោ**

**និយ្យានិកោ តំ បនមាមិ ធម្មំ ។**

ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ៨ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយា ញុំាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឱ្យត្រជាក់ រម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញុំាំងសត្វឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**

**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។**

ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌

របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

**ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ (**ធម្មោ** ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១) **សន្ទិដ្ឋិកោ** ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គ កើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឱ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

**នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ជាទីពឹងទីរលឹក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិយត្តិធម៌និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

(ក្រាបថ្វាយបង្គំម្តង)

# សង្ឃរតនប្បណាម

ថ្វាយបង្គំព្រះសង្ឃរតនៈ

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**

**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**

**ចតុណ្ណំ បុរិសយុគានំ អដ្ឋ បុរិសបុគ្គលានំ**

**អនាសវោ តំ បនមាមិ សង្ឃំ ។**

ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយ នូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះ ដោយគោរព ។

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**

**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។**

ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គនិងផល ក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផល ក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិ

តាមគន្លងព្រះនព្វលោកុត្តរធម៌ **ឧជុបដិបន្នោ ភគវតោ សាវក-សង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា **ញាយបដិបន្នោ ភគ-វតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្បៀមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេច នូវសោតាបត្តិមគ្គនិងសោតាបត្តិផល ជាគូ១ សកទាគាមិមគ្គនិងសកទាគាមិផល ជាគូ១ អនាគាមិមគ្គនិងអនាគាមិផល ជាគូ១ អរហត្តមគ្គនិងអរហត្តផល ជាគូ១ **អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ១ សោតាបត្តិផល១ សកទាគាមិមគ្គ១ សកទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរ

ទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា **ឃាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

**នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ **សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ជាទីពឹងទីរលឹក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការ គឺសម្មតិសង្ឃនិងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង **សង្ឃេ យោ ខលិតោ ទោសោ**

ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះសង្ឃជាម្ចាស់ **សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ៕

(ក្រាបថ្វាយបង្គំម្តង)

# បណាមគាថា

**យោ កប្បកោដីហិបិ អប្បមេយ្យំ**

**កាលំ ករោន្តោ អតិទុក្ករានិ**

**ខេទំ គតោ លោកហិតាយ នាថោ**

**នមោ មហាការុណិកស្ស តស្ស ។**

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ។
ធ្វើកម្មជាកម្រ មនុស្សនិករគ្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ**

**ភវាភវំ គច្ឆតិ ជីវលោកោ**

**នមោ អវិជ្ជាទិកិលេសជាលំ**

**វិទ្ធំសិនោ ធម្មវរស្ស តស្ស ។**

សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល
ឱ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។
ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្ការ
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្តាញកិលេសហើយ ។

**គុណេហិ យោ សីលសមាធិបញ្ញា-**

**វិមុត្តិញាណប្បភុតីហិ យុត្តោ**

**ខេត្តញ្ញនានំ កុសលត្ថិកានំ**

**តមរិយសង្ឃំ សិរសា នមាមិ ។**

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។

ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។

( ក្រាបថ្វាយបង្គំម្តង )

# រតនត្តយវន្ទនគាថា

**ឥច្ចេវមច្ចន្តនមស្សនេយ្យំ**
**នមស្សមានោ រតនត្តយំ យំ**
**បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ**
**តស្សានុភាវេន ហតន្តរាយោ ។**

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលុបត្រៃលោកា។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមឱ្យកម្ចាត់បង់ អពមង្គលទាំងឡាយ
ឱ្យជៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន

កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ។
ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ៕
(ក្រាបថ្វាយបង្គំម្តង)

# រតនត្តយាភិបូជាគាថា

**ឥច្ចេវមេកន្តភិបូជនេយ្យកំ**
**វត្ថុត្តយំ វន្ទយតាភិសង្ខតំ**
**បុញ្ញំ មយា យំ មម សព្ពុបទ្ទវា**
**មា ហោន្តុ វេ តស្ស បភាវសិទ្ធិយា**

វត្ថុគឺបុគ្គល គប្បីដល់ថ្វាយបូជា
ក្រៃលែងវត្ថុណា យ៉ាងប្រសើរជាក្រៃពេក ។
ខ្ញុំបានតាក់តែងកាយ បង្គំថ្វាយចិត្តត្រង់ត្រេក
រតនៈត្រៃបីជាឯក ក្នុងទីនេះសូមកុសល ។
ផលបុណ្យជួយកម្ចាត់ ឧបទ្ទវកុំជិតដល់
ចង្រៃសូមកុំយល់ សូមកុំឱ្យបង្កើតមាន ។
ដល់ខ្លួនយើងខ្ញុំណា តាំងសច្ចាជាប្រធាន

ចំណែកផលបុណ្យមាន សូមសម្រេចនិព្វានហោង ៕
(ក្រាបថ្វាយបង្គំម្តង)

# នមស្ការបូជនីយវត្ថុជាទីគោរព

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេ សុបតិដ្ឋិតំ**
**សារីរិកធាតុមហាពោធឹ ពុទ្ធរូបំ សកលំ សទា ៕**

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកម្បង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលស្ថិតនៅគ្រប់ទី ឋាននានានោះទាំងអស់ ។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ ។
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្រ ។

សូមទាន់ព្រះអរិ- យមេត្រេយ្យថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ៕
( ក្រាបថ្វាយបង្គំម្តង )

# នមស្ការពុទ្ធបាទ

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ**
**តិលោកកេតុំ តិភវេកនាថំ**
**យោ លោកសេដ្ឋោ សកលំ កិលេសំ**
**ឆេត្វាន ពោធេសិ ជនំ អនន្តំ ។**

ព្រះសព្វញ្ញូពុទ្ធ វិសេសផុតត្រៃលោកា
គ្មានមនុស្សឬទេវតា ព្រហ្មមារណាប្រដូចបាន ។
កម្ចាត់នូវកិលេស គ្មានឱ្យសេសនៅសល់ខាន
ញ៉ាំងជនទាំងប៉ុន្មាន ជាអនន្តឱ្យត្រាស់ដឹង ។
ខ្ញុំសូមថ្វាយបង្គំ នូវព្រះបរមជាទីពឹង

ព្រះអង្គឆ្លងផុតស្ទឹង បានដល់ច្រាំងនៃភពហើយ ។
ព្រះអង្គជាទង់ជ័យ ធំត្រៃឈៃបង្ហាញត្រើយ
តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។
មារព្រហ្មទាំងទេវតា និងមនុស្សរាតែងគោរព
ចូលជ្រកនៅក្រោមម្លប់ ពោធិញ្ញាណបានសុខា ។

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ**

**យំ សច្ចពន្ធគិរិកេ សុមនា ច លគ្គេ**

**យំ តត្ថ យោនកបុរេ មុនិនោ ច ធាតុំ**

**តំ បាទលញ្ឆនមហំ សិរសា នមាមិ ឳ**

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះប្រណមស្នាមបាទា
ព្រះបាទព្រះភគវា ទ្រង់មេត្តាទុកនៅនា។
បាទមួយលើផ្នូរខ្សាច់ ទៀបឆ្នេរស្ទឹងឈ្មោះនម្មទា
បាទមួយទុកនៅនា លើបព្វតាឈ្មោះសច្ចព័ន្ធ ។
បាទមួយនៅលើភ្នំ សុមនកូដដ៏សោភ័ណ
មួយទៀតទ្រង់បានជាន់ ទុកនៅក្នុងយោនកបុរី ។
ខ្ញុំសូមបន្ទន់កាយ ហត្ថាថ្វាយឱនសិរសី
ព្រះបាទព្រះជិនស្រី សូមសួស្តីគ្រប់វេលា ។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ**

## យោនកបុរេ នម្មទាយ នទិយា

## បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។

ខ្ញុំសូមនមស្ការ ឱនសិរសាអំពីចម្ងាយ
ចំពោះព្រះបាទថ្លៃ ប្រសើរក្រៃទាំងប្រាំស្ថាន ។
មួយលើកំពូលភ្នំ ដ៏ជាធំខ្ពស់ថ្កើងថ្កាន
សុវណ្ណមាលិកឋាន ព្រះទ្រង់ឈានជាន់កំណត់ ។
មួយលើកំពូលភ្នំ ដ៏ឧត្តមសុវណ្ណបព៌ត
មួយលើភ្នំប្រាកដ សុមនកូដជាទីបី ។
មួយស្ថិតនៅរាជស្ថាន ដ៏ថ្កើងថ្កានយោនកបុរី
មួយស្ថិតក្បែរជលស័យ ទៀបនទីស្ទឹងនម្មទា ។
ទុកឱ្យពួកសព្វសត្វ បានប្រតិបត្តិគ្រប់វេលា
សន្សំសុខសោភា តាមសទ្ធាជ្រះថ្លាហោង ៕

(ក្រាបថ្វាយបង្គំម្តង)

# នមស្ការបែបសង្ខេប

(ព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណសង្ខេប)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ (សូត្រ ៣ ចប់)

(ប្ដេជ្ញាកាន់យកត្រៃសរណគមន៍អស់មួយជីវិតដរាបដល់និព្វាន)

ពុទ្ធំ ជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។

ធម្មំ ជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។

សង្ឃំ ជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។

ទុតិយម្បិ ពុទ្ធំ ជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។

ទុតិយម្បិ ធម្មំ ជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។

ទុតិយម្បិ សង្ឃំ ជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។

តតិយម្បិ ពុទ្ធំ ជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។

តតិយម្បិ ធម្មំ ជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។

តតិយម្បិ សង្ឃំ ជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។

(ព្រះពុទ្ធគុណ)

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ

ភគវាតិ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។ (ថ្វាយបង្គំម្តង)

(ព្រះធម្មគុណ)

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ។ (ថ្វាយបង្គំម្តង)

(ព្រះសង្ឃគុណ)

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ។

(ថ្វាយបង្គំម្តង)

# ខមាទោសព្រះរតនត្រ័យ

**កាយេន វាចាយ វ ចេតសា វា**

**ពុទ្ធេ កុកម្មំ បកតំ មយា យំ**

**ពុទ្ធោ បដិគ្គណ្ហាតុ អច្ចយន្តំ**

**កាលន្តរេ សំវរិតុំ វ ពុទ្ធេ ។**

កម្មណាដែលខ្ញុំធ្វើ អាក្រក់លើព្រះពុទ្ធពិត
ដោយកាយវាចាចិត្ត សុចរិតឥតបារម្ភ ។
ពុទ្ធោសូមព្រះពុទ្ធ ទ្រង់អំណត់អត់ទោសខ្ញុំ
ខុសឆ្គងព្រះពុទ្ធកុំ យកទោសខ្ញុំតទៅទៀត ។
ដើម្បីនឹងសង្រួម រវាំងព្រមមិនឱ្យឃ្លាត
ចេញពីព្រះពុទ្ធទៀត ឱ្យបានសព្វកាលទៅហោង។

**កាយេន វាចាយ វ ចេតសា វា**

**ធម្មេ កុកម្មំ បកតំ មយា យំ**

**ធម្មោ បដិគ្គណ្ហាតុ អច្ចយន្តំ**

**កាលន្តរេ សំវរិតុំ វ ធម្មេ ។**

កម្មណាដែលខ្ញុំធ្វើ អាក្រក់លើព្រះធម៌ពិត
ដោយកាយវាចាចិត្ត សុចរិតឥតបារម្ភ ។

ព្រះធម៌ជាមកុដ ទ្រង់អំណត់អត់ទោសខ្ញុំ
ខុសឆ្គងព្រះធម៌កុំ យកទោសខ្ញុំតទៅទៀត ។
ដើម្បីនឹងសង្រួម រវាំងព្រមមិនឱ្យឃ្លាត
ចេញពីព្រះធម៌ទៀត ឱ្យបានសព្វកាលទៅហោង។

**កាយេន វាចាយ វ ចេតសា វា**

**សង្ឃេ កុកម្មំ បកតំ មយា យំ**

**សង្ឃោ បដិគ្គណ្ហតុ អច្ចយន្តំ**

**កាលន្តរេ សំវរិតុំ វ ពុទ្ធេ ឋ**

កម្មណាដែលខ្ញុំធ្វើ អាក្រក់លើព្រះសង្ឃពិត
ដោយកាយវាចាចិត្ត សុចរិតឥតបារម្ភ ។
ព្រះសង្ឃអង្គបរិសុទ្ធ ទ្រង់អំណត់អត់ទោសខ្ញុំ
ខុសឆ្គងព្រះសង្ឃកុំ យកទោសខ្ញុំតទៅទៀត ។
ដើម្បីនឹងសង្រួម រវាំងព្រមមិនឱ្យឃ្លាត
ចេញពីព្រះសង្ឃទៀត ឱ្យបានសព្វកាលទៅហោង។

# ផ្សាយមេត្តាចំពោះទិសទាំង១០

**សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបូព៌ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសអាគ្នេយ៍ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសទក្សិណ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសនិរតី សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបស្ចិម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសពាយ័ព្យ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឧត្តរ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឦសាន សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងក្រោម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងលើ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ សត្តា អវេរា ហោន្តុ** សូមឱ្យសត្វទាំងឡាយទាំងពួង កុំមានពៀរនឹងគ្នាន ។

**សុខិតា ហោន្តុ** សូមឱ្យបាននូវសេចក្តីសុខ ។

**និទ្ទុក្ខា ហោន្តុ** សូមកុំឱ្យមានទុក្ខ ។

**អព្យាបជ្ឈា ហោន្តុ** សូមកុំឱ្យបៀតបៀនដល់គ្នានឹងគ្នា ។

**អនីឃា ហោន្តុ** សូមកុំឱ្យមានសេចក្តីព្រួយលំបាក ។

**ទីឃាយុកា ហោន្តុ** សូមឱ្យមានអាយុវែង ។

**អរោគា ហោន្តុ** សូមកុំឱ្យមានរោគ ។

**សម្បត្តិហី សមិជ្ឈន្តុ** សូមឱ្យសម្រេចដោយសម្បត្តិគ្រប់យ៉ាង ។

**សុខី អត្តានំ បរិហរន្តុ** សូមឱ្យរក្សានូវខ្លួនជាសុខស្រួលចុះ

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ៗ**

សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅហោង ។

(ក្រាបថ្វាយបង្គំម្តង)

# អនុមោទនារក្ខាយាចនគាថា

**អាកាសដ្ឋា ច ភុម្មដ្ឋា    ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ    ចិរំ រក្ខន្តុ សាសនំ ៗ**

ទេវតាទាំងឡាយ ដែលស្ថិតឰដ៏អាកាសក្តី ដែលស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ ដែលមានឫទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវព្រះពុទ្ធសាសនា (ឱ្យស្ថិតស្ថេរនិងឱ្យរុងរឿង) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា    ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ    ចិរំ រក្ខន្តុ រដ្ឋកេ ៗ**

ទេវតាទាំងឡាយ ដែលស្ថិតឰដ៏អាកាសក្តី ដែលស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ ដែលមានឫទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវមហាជនក្នុងរដ្ឋទាំងឡាយ ឱ្យបានសេចក្តីសុខចម្រើន អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា    ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ    ចិរំ រក្ខន្តុ ញាតយោ ៗ**

ទេវតាទាំងឡាយ ដែលស្ថិតឰដ៏អាកាសក្តី ដែលស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ ដែលមានឫទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវ

បុណ្យរបស់យើងទាំងឡាយ សូមរក្សានូវញាតិទាំងឡាយ ឱ្យបាន សេចក្តីសុខចម្រើន អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាណិនោ ៗ**

ទេវតាទាំងឡាយ ដែលស្ថិតឰដ៏អាកាសក្តី ដែលស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ ដែលមានឫទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវសត្វទាំងឡាយ ឱ្យបាន សេចក្តីសុខចម្រើន អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ៗ**

ទេវតាទាំងឡាយ ដែលស្ថិតឰដ៏អាកាសក្តី ដែលស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ ដែលមានឫទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវយើងទាំងឡាយ ឱ្យបាន សេចក្តីសុខចម្រើន អស់កាលជាយូរអង្វែងទៅ ។

(ក្រាបថ្វាយបង្គំម្តង)

# សុមង្គលគាថា

**ហោតុ សព្វំ សុមង្គលំ** សុមង្គល គឺសេចក្ដីចម្រើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ

**រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ

**សព្វពុទ្ធានុភាវេន** ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ

**សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង

**សព្វសង្ឃានុភាវេន** ដោយអានុភាពនៃព្រះសង្ឃទាំងពួង

**សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តីចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ៕

( ក្រាបថ្វាយបង្គំម្តង )

# បត្តិទានគាថា

ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា
អាចរិយូបការា ច មាតាបិតា បិយា មមំ
សុរិយោ ចន្ទិមា រាជា គុណវន្តា នរាបិ ច

ព្រហ្មា មារា ច ឥន្ទ្រា ច    លោកបាលា ច ទេវតា
យមោ មិត្តា មនុស្សា ច    មជ្ឈត្តា វេរិកាបិ ច
សព្វេ សត្តា សុខី ហោន្តុ    បុញ្ញានិ បកតានិ មេ
សុខញ្ច តិវិធំ ទេន្តុ    ខិប្បំ បាបេថ វោមតំ ។
ឥមិនា បុញ្ញកម្មេន    ឥមិនា ឧទ្ទិសេន ច
ខិប្បាហំ សុលភេ ចេវ    តណ្ហុប្បាទានឆេទនំ
យេ សន្តានេ ហីនា ធម្មា    យាវ និព្វានតោ មមំ
នស្សន្តុ សព្វទាយេវ    យត្ថ ជាតោ ភវាភវេ
ឧជុចិត្តោ សតិប្បញ្ញោ    សល្លេខោ វីរិយោម្ហិ វា
មារា លភន្តុ នោកាសំ    កាតុញ្ច វីរិយេសុ មេ
ពុទ្ធោ ទីបវរោ នាថោ    ធម្មោ នាថោ វរុត្តមោ
នាថោ បច្ចេកពុទ្ធោ ច    សង្ឃោ នាថោត្តរោ មមំ
តេសោត្តមានុភាវេន    មារោកាសំ លភន្តុ មា ។

## ខមាបនគាថា

យេ កេចិ ខុទ្ទកា បាណា    មហន្តាបិ មយា ហតា
យេ បាណេកេ បមាទេន    កាយវាចាមនេហិ វា

បុញ្ញំ មេ អនុមោទន្តុ គណ្ហន្តុ ផលមុត្តមំ
វេរិនោ ចេ បមុញ្ចន្តុ សព្វទោសំ ខមន្តុ មេ ។

## បត្តិទានគាថា

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម
កាយេន វាចាមនសា តិទសេ សុគតំ កតំ ។
យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ ។
យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ ។
សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។

## បត្តិទានគាថា (ប្រែជាពាក្យកាព្យ)

កម្មកុសលឯណា ដែលជាការឥតសៅហ្មង
យើងខ្ញុំបានកសាង ដោយទ្វារកាយវាចាចិត្ត ។
កុសលទាំងអស់នោះ អាចជួយដោះជួយបង្ខិត
នាំសត្វឲ្យជាប់ចិត្ត ស្ថិតនៅនាស្ថានឧត្តម ។

សត្វណាមានសញ្ញា មនុស្សទេព្តាឬឥន្ទព្រហ្ម
ដែលមានស័ក្តិតូចធំ ព្រមទាំងសត្វឥតសញ្ញា ។
សូមបានចំណែកបុណ្យ ដែលជាគុណល្អថ្លៃថ្លា
យើងខ្ញុំបានរចនា ចាត់ចែងការកុសលហ្នឹង ។
ម្យ៉ាងទៀតសត្វឯណា ឆ្ងាយអស្ចារ្យពុំបានដឹង
សូមទេព្តាទៅប្តឹង ឲ្យដំណឹងយ៉ាងនេះថា ។
នរជននៅឯណោះ ស្រីឬប្រុសបានជ្រះថ្លា
សាងបុញ្ញកិរិយា វត្ថុជាផ្លូវឆើតឆាយ ។
ហើយគេឧទ្ទិសផល ឲ្យបានដល់អ្នកទាំងឡាយ
ចូរមានចិត្តស្រស់ស្រាយ បន្ទន់កាយទទួលយក ។
សត្វលោកទាំងអស់នោះ ដែលបានរស់តរៀងមក
ដោយបានបរិភោគ នូវអាហារទើបរស់បាន ។
សត្វទាំងអស់នោះណា បានសុខាសព្វគ្រប់ប្រាណ
អាហារយ៉ាងចំណាន សូមឲ្យបានកុំខានឡើយ ៕

# បត្តិទានគាថាប្រែ

រីទានខ្ញុំធ្វើហើយ ព្រះគុណអើយខ្ញុំសច្ចា
ឧទ្ទិសផលនេះណា ជូនមាតាបិតាខ្ញុំ ។
ជីដូននិងជីតា គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម មកជួបជុំទទួលផល ។

ដែលកូនចៅបានធ្វើ នូវអំពើជាកុសល
សូមទានឲ្យបានដល់ ទោះមណ្ឌលឆ្ងាយយ៉ាងណា ។
កុសលទាំងអស់ហ្នឹង សូមទីពឹងលើទេវតា
សូមមានចិត្តមេត្តា នាំផលាទាំងអស់នេះ ។
ទៅជូនឲ្យខ្ញុំផង ដូចបំណងកុំបីធ្វេស
កូនចៅនៅឯណេះ មិនប្រហែសបញ្ជូនមក ។
សូមមានចិត្តរីករាយ ដោយសប្បាយទទួលយក
កូនចៅបានលៃលក បញ្ជូនមកលោកគ្រប់គ្នា ។
ដើម្បីសោយផលទាន សូមឲ្យបាននូវសុខជា
កូនចៅទាំងអស់គ្នា បានបូជាជូនទៅហោង ៕

# បត្តិទានគាថា

យា ទេវតា សន្តិ វិហារវាសិនី
ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ
តា ធម្មទានេន ភវន្តុ បូជិតា
សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ
ថេរា ច មជ្ឈា នវកា ច ភិក្ខវោ
សារាមិកា ទានបតី ឧបាសកា
គាមា ច ទេសា និគមា ច ឥស្សរា
សប្បាណភូតា សុខិតា ភវន្តុ តេ
ជលាពុជា យេបិ ច អណ្ឌសម្ភវា
សំសេទជាតា អថវោបបាតិកា
និយ្យានិកំ ធម្មវរំ បដិច្ច តេ
សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ ។

ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា
សង្ឃោ ហោតុ សមគ្គោ វ អត្ថាយ ច ហិតាយ ច
អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ

វុឌ្ឍី សម្បាបុណោយ្យាម ធម្មារិយប្បវេទិតេ ៕

## បត្តិទានគាថា (បាលី - ប្រែ)

**យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ** ទេវតាទាំងឡាយឯណា មានប្រក្រតីនៅក្នុងទីវត្តជាទីនៅនៃសង្ឃ ឮដ៏ខឿនព្រះសថូប ឮដ៏ខឿនព្រះពោធិព្រឹក្ស ក្នុងទីនោះៗ **តា ធម្មទានេន ភវន្តុ បូជិតា** ទេវតាទាំងឡាយនោះ ជាបុគ្គលគឺយើងទាំងឡាយបូជាហើយដោយធម្មទាន **សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ** ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្តជាទីនៅនៃព្រះសង្ឃនេះ **ថេរា ច មជ្ឈា នវកា ច ភិក្ខវោ** ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី **សារាមិកា ទានបតី ឧបាសកា** ឧបាសកនិងឧបាសិកាទាំងឡាយ ដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជន គឺញោមវត្តក្តី **គាមា ច ទេសា និគមា ច ឥស្សរា** ជនទាំងឡាយ ដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈជាធំក្តី **សប្បាណភូតា សុខិតា ភវន្តុ តេ** សត្វទាំងឡាយនោះៗ ចូរឱ្យបានដល់នូវសេចក្តីសុខ

**ជលាពុជា យេបិ អណ្ឌសម្ភវា សំសេទជាតា អថោ-បបាតិកា** មួយវិញទៀត សត្វទាំងឡាយឯណា ដែលជាជលាពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឧបបាតិកៈកំណើតក្តី **និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ** សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យហើយនូវធម៌ដ៏ប្រសើរ ជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅ នៃទុក្ខចុះ **ឋាតុ ចិរំ សតំ ធម្មោ** សូមឱ្យធម៌របស់សប្បុរសទាំងឡាយស្ថិតនៅអស់កាលជាយូរអង្វែងទៅ **ធម្មធរា ច បុគ្គលា** បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរស្ថិតនៅអស់កាលយូរអង្វែងតទៅ) **សង្ឃោ ហោតុ សមគ្គោ វ** សូមព្រះសង្ឃព្រមព្រៀងគ្នា **អត្ថាយ ច ហិតាយ ច** ដើម្បីសេចក្តីចម្រើនផង ដើម្បីសេចក្តីសម្រេចផលប្រយោជន៍ផង **អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ** សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង **វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ** សូមឱ្យយើង

ទាំងឡាយ បានដល់នូវសេចក្ដីចម្រើន ក្នុងធម៌ដែលព្រះអរិយៈទាំងឡាយ លោកសម្ដែងហើយ ។

# តេជៈខ្ញុំសាង

តេជៈខ្ញុំសាង សម្ផិតសម្ផាង ឱនកាយវាចា
សូមសុខសោភា រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន ។

គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីលនិងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ឋានថ្លៃថ្លា ។

សូមជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញាតកា
គ្រប់ផៅសន្ដាន ។

ជីដូនជីតា រស់នៅក្ដីណា លោកម្ចាស់ចែកស្ថាន
ខ្ញុំជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ ។

ខ្ញុំសូមប្រាថ្នា សច្ចៈវាចា បានឆ្លងទៅមុខ
សូមមានប្រាជ្ញា ភ្លឺថ្លាមោះមុត ឆ្លងរួចផុតទុក្ខ
ដល់និព្វានហោង ។

# បារមីទាំង ៣០

ឥតិបិ ទានបារមី សម្បន្នោ សោ ភគវា

ឥតិបិ ទានឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ ទានបរមត្ថបារមី សម្បន្នោ សោ ភគវា

ឥតិបិ សីលបារមី សម្បន្នោ សោ ភគវា

ឥតិបិ សីលឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ សីលបរមត្ថបារមី សម្បន្នោ សោ ភគវា

ឥតិបិ នេក្ខម្មបារមី សម្បន្នោ សោ ភគវា

ឥតិបិ នេក្ខម្មឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ នេក្ខម្មបរមត្ថបារមី សម្បន្នោ សោ ភគវា

ឥតិបិ បញ្ញាបារមី សម្បន្នោ សោ ភគវា

ឥតិបិ បញ្ញាឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ បញ្ញាបរមត្ថបារមី សម្បន្នោ សោ ភគវា

ឥតិបិ វីរិយបារមី សម្បន្នោ សោ ភគវា

ឥតិបិ វីរិយឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ វីរិយបរមត្ថបារមី សម្បន្នោ សោ ភគវា

ឥតិបិ ខន្តិបារមី សម្បន្នោ សោ ភគវា

ឥតិបិ ខន្តិឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ ខន្តិបរមត្ថបារមី សម្បន្នោ សោ ភគវា

ឥតិបិ សច្ចបារមី សម្បន្នោ សោ ភគវា

ឥតិបិ សច្ចឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ សច្ចបរមត្ថបារមី សម្បន្នោ សោ ភគវា

ឥតិបិ អធិដ្ឋានបារមី សម្បន្នោ សោ ភគវា

ឥតិបិ អធិដ្ឋានឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ អធិដ្ឋានបរមត្ថបារមី សម្បន្នោ សោ ភគវា

ឥតិបិ មេត្តាបារមី សម្បន្នោ សោ ភគវា

ឥតិបិ មេត្តាឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ មេត្តាបរមត្ថបារមី សម្បន្នោ សោ ភគវា

ឥតិបិ ឧបេក្ខាបារមី សម្បន្នោ សោ ភគវា

ឥតិបិ ឧបេក្ខាឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ ឧបេក្ខាបរមត្ថបារមី សម្បន្នោ សោ ភគវា

ឥតិបិ ទសបារមី សម្បន្នោ សោ ភគវា

ឥតិបិ ទសឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ ទសបរមត្ថបារមី សម្បន្នោ សោ ភគវា
ឥតិបិ សមតឹសបារមី សម្បន្នោ សោ ភគវាតិ ។

## ទសបារមី ( បាលី - ប្រែ )

**ឥតិបិ ទានបារមី សម្បន្នោ សោ** ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយទានបារមី ។

**ឥតិបិ ទានឧបបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយទានឧបបារមី ។

**ឥតិបិ ទានបរមត្ថបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយទានបរមត្ថបារមី ។

**ឥតិបិ សីលបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយសីលបារមី ។

**ឥតិបិ សីលឧបបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយសីលឧបបារមី ។

**ឥតិបិ សីលបរមត្ថបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយសីលបរមត្ថបារមី។

**ឥតិបិ នេក្ខម្មបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយនេក្ខម្មបារមី ។

**ឥតិបិ នេក្ខម្មឧបបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយនេក្ខម្មឧបបារមី ។

**ឥតិបិ នេក្ខម្មបរមត្ថបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយនេក្ខម្មបរមត្ថបារមី

**ឥតិបិ បញ្ញាបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយបញ្ញាបារមី ។

**ឥតិបិ បញ្ញាឧបបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយបញ្ញាឧបបារមី ។

**ឥតិបិ បញ្ញាបរមត្ថបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយបញ្ញាបរមត្ថបារមី។

**ឥតិបិ វីរិយបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយវីរិយបារមី ។

**ឥតិបិ វីរិយឧបបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយវីរិយឧបបារមី ។

**ឥតិបិ វីរិយបរមត្ថបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយវីរិយបរមត្ថបារមី ។

**ឥតិបិ ខន្តិបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគ អង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយខន្តិបារមី ។

**ឥតិបិ ខន្តិឧបបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយខន្តិឧបបារមី ។

**ឥតិបិ ខន្តិបរមត្ថបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយខន្តិបរមត្ថបារមី ។

**ឥតិបិ សច្ចបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគ អង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយសច្ចបារមី ។

**ឥតិបិ សច្ចឧបបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយសច្ចឧបបារមី ។

**ឥតិបិ សច្ចបរមត្ថបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយសច្ចបរមត្ថបារមី ។

**ឥតិបិ អធិដ្ឋានបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយអធិដ្ឋានបារមី ។

**ឥតិបិ អធិដ្ឋានឧបបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយអធិដ្ឋាឧបបារមី ។

**ឥតិបិ អធិដ្ឋានបរមត្ថបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយអធិដ្ឋានបរមត្ថបារមី ។

**ឥតិបិ មេត្តាបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយមេត្តាបារមី ។

**ឥតិបិ មេត្តាឧបបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយមេត្តាឧបបារមី ។

**ឥតិបិ មេត្តាបរមត្ថបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយមេត្តាបរមត្ថបារមី។

**ឥតិបិ ឧបេក្ខាបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយឧបេក្ខាបារមី ។

**ឥតិបិ ឧបេក្ខាឧបបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយឧបេក្ខាឧបបារមី ។

**ឥតិបិ ឧបេក្ខាបរមត្ថបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយឧបេក្ខាបរមត្ថបារមី

**ឥតិបិ ទសបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយទសបារមី ។

**ឥតិបិ ទសឧបបារមី សម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយទសឧបបារមី ។

**ឥតិបិ ទសបរមត្ថបារមី សម្បន្នោ សោ ភគវា** ដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយទសបរមត្ថបារមី ។

**ឥតិបិ សមតឹសបារមី សម្បន្នោ សោ ភគវាតិ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយ ដោយបារមីសាមសិបប្រការយ៉ាងនេះឯង។

## ភាសិតោវាទ សង្ខេប

**ឱកាស!** ខ្ញុំសូមគោរព

**យោ បន ធម្មានុធម្មបដិបន្នោ វិហរតិ សាមីចិ-បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ការោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ ។**

អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះថាធ្វើសក្ការៈ ធ្វើសេចក្ដីគោរពរាប់អានបូជា នូវព្រះតថាគតដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម

**សព្វបាបស្ស អករណំ   កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ   ឯតំ ពុទ្ធាន សាសនំ ។**

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**ខន្តី បរមំ តបោ តីតិក្ខា**
**និព្វានំ បរមំ វទន្តិ ពុទ្ធា**
**ន ហិ បព្វជិតោ បរូបឃាតី**
**សមណោ ហោតិ បរំ វិហេឋយន្តោ ។**

អំណត់គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតដ៏ឧត្តម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

**អនូបវាទោ អនូបឃាតោ  បាតិមោក្ខេ ច សំវរោ**
**មត្តញ្ញុតា ច ភត្តស្មឹ  បន្តញ្ច សយនាសនំ**
**អធិចិត្តេ ច អាយោគោ  ឯតំ ពុទ្ធាន សាសនំ ។**

កិរិយាមិនតិះដៀល (អ្នកដទៃ)១ កិរិយាមិនបៀតបៀន (អ្នកដទៃ)១ កិរិយាសង្រួមក្នុងបាតិមោក្ខ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ១ ទីដេកនិងទីអង្គុយដ៏ស្ងាត់១ កិរិយាបំពេញព្យាយាម

ក្នុងអធិចិត្ត ១ ទាំងនេះជាពាក្យប្រៀនប្រដៅ នៃព្រះពុទ្ធ ទាំងឡាយ ។

**សីលសមាធិគុណានំ ខន្តិ បធានការណំ**

**សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិ តេ ។**

សេចក្តីអត់ធន់ ជាហេតុជាទីតាំង នៃគុណគឺសីលនិងសមាធិ ទាំងឡាយ ធម៌ទាំងឡាយជាកុសល ទាំងអស់នោះ តែងចម្រើន ដោយសេចក្តីអត់ធន់មែនពិត។

**កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**

**គរហកលហាទីនំ មូលំ ខណតិ ខន្តិកោ ។**

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំង អស់ បុគ្គលអ្នកអត់ធន់ ឈ្មោះថាជីករំលើង នូវឫសនៃទោស ទាំងឡាយ មានពាក្យតិះដៀលនិងការឈ្លោះប្រកែកជាដើម ។

**ខន្តិ ធីរស្ស លង្ការោ ខន្តិ តបោ តបស្សិនោ**

**ខន្តិ ពលំ វ យតីនំ ខន្តិ ហិតសុខាវហា ។**

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ ជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែលមានតបធម៌ សេចក្តីអត់ ធន់ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្តីអត់ធន់ ជាគុណជាតិ នាំមកនូវប្រយោជន៍និងសេចក្តីសុខ ។

**ខន្តិកោ មេត្តវា លាភី   យសស្សី សុខសីលវា**

**បិយោ ទេវមនុស្សានំ   មនាបោ ហោតិ ខន្តិកោ ។**

អ្នកអត់ធន់ ជាអ្នកមានមិត្រសំឡាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកអត់ធន់រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្ត នៃទេវតានិងមនុស្សទាំងឡាយ ។

**អត្តនោបិ បរេសញ្ច   អត្ថាវហោវ ខន្តិកោ**

**សគ្គមោក្ខគមំ មគ្គំ   អារុឡ្ហោ ហោតិ ខន្តិកោ ។**

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង អ្នកអត់ធន់ជាអ្នកឡើងកាន់ផ្លូវជាទីទៅស្ថានសួគ៌និងព្រះនិព្វាន ។

**សត្ថុនោ វចនោវាទំ   ករោតិយេវ ខន្តិកោ**

**បរមាយ ច បូជាយ   ជិនំ បូជេតិ ខន្តិកោ ។**

អ្នកអត់ធន់ ឈ្មោះថាធ្វើតាមនូវព្រះពុទ្ធដីកា ជាឱវាទនៃព្រះ-សាស្តាមែនពិត អ្នកអត់ធន់ឈ្មោះថា បូជានូវព្រះវិជិតមារ ដោយការបូជាដ៏ឧត្តម ។

**ទុល្លភញ្ច មនុស្សត្តំ   ពុទ្ធុប្បាទោ ច ទុល្លភោ**

**ទុល្លភា ខណសម្បត្តិ   សទ្ធម្មោ បរមទុល្លភោ ។**

ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយបានដោយកម្រ កិរិយាត្រាស់ជាព្រះពុទ្ធ គឺសត្វទាំងឡាយបានដោយកម្រ កិរិយាដល់ព្រមដោយខណៈ គឺបានកើតជួបនឹងព្រះពុទ្ធ ឬនឹងព្រះពុទ្ធសាសនា គឺសត្វទាំងឡាយបានដោយកម្រ ធម៌របស់សប្បុរស គឺសត្វទាំងឡាយបានដោយកម្រក្រៃលែង ។

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា**

**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។**

កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ កិរិយាសម្តែង នូវធម៌របស់សប្បុរស នាំមកនូវសេចក្តីសុខ សេចក្តីព្រមព្រៀងគ្នា របស់សង្ឃឬពួកក្រុម នាំមកនូវសេចក្តីសុខ សេចក្តីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយ នាំមកនូវសេចក្តីសុខ ។

**សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ**

**អព្យាបជ្ជំ សុខំ លោកេ បាណភូតេសុ សញ្ញមោ**

សេចក្តីស្ងប់ស្ងាត់ របស់អ្នកដែលត្រេកអរ(ក្នុងទីស្ងាត់) ជាអ្នកមានធម៌បានស្តាប់ហើយ ពិចារណាឃើញ(នូវធម៌) នាំមកនូវសេចក្តីសុខ កិរិយាមិនបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក ។

**សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ**

**អស្មិមានស្ស វិនយោ	ឯតំ វេ បរមំ សុខំ ។**

ភាវៈប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្ដីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាសនូវអស្មិមានៈ នេះឯងនាំមកនូវសេចក្ដីសុខដ៏ឧត្ដម ។

**កិច្ឆោ មនុស្សបដិលាភោ	កិច្ឆំ មច្ចាន ជីវិតំ**

**កិច្ឆំ សទ្ធម្មស្សវនំ	កិច្ឆោ ពុទ្ធានមុប្បាទោ**

កិរិយាត្រឡប់បានអត្តភាពជាមនុស្ស ជាការលំបាក សេចក្ដីរស់នៅរបស់សត្វទាំងឡាយ ជាការលំបាក កិរិយាស្ដាប់នូវព្រះសទ្ធម្ម ជាការកម្រ កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ ជាការលំបាក ។

**សត្ថុនោ សទ្ធម្មំ សុត្វា	សព្វស្មឹ ជិនសាសនេ**

**កប្បានិ សតសហស្សានិ	ទុគ្គតឹ សោ ន គច្ឆតិ ។**

បុគ្គលឯណាបានស្ដាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្ដា (ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅ នៃព្រះវិជិតមារទាំងពួង បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិ អស់សែនកប្ប ។

**បុព្វណ្ហេ បិណ្ឌបាតញ្ច	សាយណ្ហេ ធម្មទេសនំ**

**បទោសេ ភិក្ខុឱវាទំ	អឌ្ឍរត្តេ ទេវបញ្ហានំ**

**បច្ចូសេវ គតេ កាលេ	ភព្វាភព្វេ វិលោកនំ**

**ឯតេ បញ្ចវិធេ កិច្ចេ     វិសោធេតិ មុនិបុង្គវោតិ**

ព្រះសម្មាសម្ពុទ្ធជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជម្រះនូវពុទ្ធកិច្ចទាំងឡាយ៥ ប្រការនេះ គឺក្នុងពេលព្រឹក ទ្រង់ស្ដេចទៅបិណ្ឌបាត១ ក្នុងពេលល្ងាច ទ្រង់សម្ដែងធម៌ទេសនា១ ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ១ ក្នុងពេលអធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា១ ក្នុងពេលជិតភ្លឺ ទ្រង់ប្រមើលនូវសត្វលោក ដែលគួរត្រាស់ដឹងនិងមិនគួរត្រាស់ដឹង១ ។

**កុក្កុដេ គព្ភវាសោ ច     សោណេ ចុទរនិក្ខមិ**

**ខុសភេ  រាជសម្បត្តិ     សសេ បព្វជិតោ ជិនោ ។**

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះគភ៌ (នៃព្រះវររមាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូតចាកព្រះគភ៌ក្នុងឆ្នាំច ទ្រង់សោយរាជសម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ ។

**កុក្កុដេ សព្វញ្ញូ ពុទ្ធោ     តត្ថ ចក្កំ បវត្តយិ**

**និព្វានគមនំ សប្បេ     សហស្សំ បញ្ច មូសិកេ ។**

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងឆ្នាំរកា ទ្រង់សម្ដែងនូវព្រះធម្មចក្រក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនានឹងគ្រប់ ៥,០០០ ក្នុងឆ្នាំជូត ។

**ឱក្កន្តោ ច គរុវារស្មឹ     សុក្កវារេ ច និក្ខមិ**

**សម្ពុទ្ធោ ពុធវារស្មឹ អង្គារេ បរិនិព្វុតោ ។**

ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពុធ បរិ-និព្វានក្នុងថ្ងៃអង្គារ ។

**អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេយេវ និក្ខមិ**

**វិសាខបុណ្ណមីសម្ពុទ្ធោ វិសាខេ បរិនិព្វុតោ ។**

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃពេញបូណ៌មីខែអាសាឍ ប្រសូតក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បានត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បរិនិព្វានក្នុងថ្ងៃពេញបូណ៌មីខែវិសាខ ។

**និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ**

**បដិមា ពោធិរុក្ខោ ច ថូបា ច ជិនធាតុយោ**

**ចតុរាសីតិសហស្ស- ធម្មក្ខន្ធា សុទេសិតា**

**អគ្គប្បវត្តនដ្ឋានេ ឋបិតា ហោន្តិ ចាណិនំ ។**

កាលព្រះសម្មាសម្ពុទ្ធជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិ-និព្វានទៅហើយ ព្រះបដិមាផង ពោធិព្រឹក្សផង ព្រះសថូបផង ព្រះជិនធាតុផង ព្រះធម៌៨ហ្មឺន ៤ពាន់ព្រះធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សម្ដែងហើយដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធ ទ្រង់

ប្រតិស្ឋានទុក ក្នុងស្ថានដ៏ប្រព្រឹត្តទៅដើម្បីជាបុញ្ញក្ខេត្ត ដ៏ប្រសើររបស់សត្វទាំងឡាយ ។

**ឥតិ សម្មាសម្ពុទ្ធេន ទេសិតំ ឱវាទំ ចិត្តេ ឋបេត្វា សម្មាសម្ពុទ្ធេន វុត្តប្បការេន បដិបត្តិបូជាយ បូជិ ករោន្តេន លោកិយលោកុត្តរសម្បត្តិសិទ្ធំ កាតព្វំ ឱកាស អារាធនំ ករោមិ ២**

បុគ្គលគួរតម្កល់នូវឱវាទ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងហើយទុកក្នុងចិត្ត ហើយធ្វើការបូជាដោយបដិបត្តិបូជា ដោយនូវប្រការដែលព្រះសម្មាសម្ពុទ្ធ ត្រាស់សម្ដែងហើយ គួរធ្វើឱ្យសម្រេចនូវសម្បត្តិជាលោកិយ និងលោកុត្តរ ខ្ញុំសូមគោរពអារាធនាទុកដោយប្រការដូច្នេះ ។

(ក្រាបថ្វាយបង្គំម្ដង)

**ឱកាស សិរីសក្យមុនិសព្វញ្ញុពុទ្ធស្ស ពលវប្បច្ចូស-សមយេ កុសិនារាយ យមកសាលានមន្តរេ អមុម្ហិ សប្បសំវច្ឆរេ គិម្ហឧតុម្ហិ វិសាខមាសេ សុក្កបក្ខេ បណ្ណរសិយា តិថិយំ ភុម្មវារេ ភុម្មយាមេ អនុរាធនក្ខត្ត-**

**និវសេ បរិនិព្វានំ អហោសិ អនុបាទិសេសាយ និព្វានធាតុយា ឞ**

ខ្ញុំសូមគោរព សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះសាលព្រឹក្សទាំងគូជិតក្រុងកុសិនារា ក្នុងបច្ចូសសម័យ ដ៏មានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តឫក្សឈ្មោះអនុរាធា ក្នុងថ្ងៃអង្គារ យាមអង្គារ ជាតិថីពេញបូណ៌មីខាងខ្នើតខែវិសាខក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ឯណោះ ហោង ។

(តពីនេះទៅត្រូវបកសករាជប្រាប់ថ្ងៃ ខែ ឆ្នាំដែលកន្លងហើយ បច្ចុប្បន្ន និងអនាគត ដរាបដល់ចប់) ។

## បច្ឆិមពុទ្ធវចនៈ

**យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ** ម្នាលអានន្ទ សភាវៈឯណា គឺព្រះធម៌ក្តី ព្រះវិន័យក្តី ដែលតថាគតបានសម្តែងហើយ បានបញ្ញត្តហើយ ដល់អ្នកទាំងឡាយ ។

**សោ វោ មមច្ចយេន សត្ថា** សភាវៈគឺព្រះធម៌និងព្រះវិន័យនោះ លុះអំណើះឥតអំពីតថាគតទៅហើយ នឹងបានជាគ្រូប្រៀនប្រដៅនូវអ្នកទាំងឡាយ។

**អហំ ឯតរហិ បរិនិព្វាយិស្សាមិ** តថាគតជាព្រះពុទ្ធមួយអង្គឯងពិត នឹងបរិនិព្វានទៅ ។

**អហញ្ហិ បនិទានិ ឯតរហិ ឱវទាមិ អនុសាសេមិ** តែថាឥឡូវនេះ តថាគតជាព្រះពុទ្ធមួយអង្គឯងពិត តែងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

**មយិ បរិនិព្វុតេ** កាលបើតថាគតបរិនិព្វានទៅហើយ **ឥមានិ ចតុរាសីតិធម្មក្ខន្ធសហស្សានិ តុម្ហេ ឱវទិស្សន្តិ អនុសាសិស្សន្តិ** ព្រះធម្មក្ខន្ធប្រាំបីហ្មឺនបួនពាន់នេះ នឹងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយ ជាខាងក្រោយ ។

**យោ កោចិ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិបដិបន្នោ អនុធម្មចារី** ម្នាលអានន្ទ បុគ្គលឯណាមួយ គឺភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិធម៌វិន័យតាមសមគួរដល់ធម៌វិន័យ ជាអ្នកប្រតិបត្តិ ដោយសេចក្តីគោរពកោតក្រែងដល់ធម៌វិន័យ ប្រព្រឹត្តតាមធម៌វិន័យជាប្រក្រតី ។

**សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ** បុគ្គលទាំងអស់នោះ បាន

ឈ្មោះថាធ្វើសក្ការៈនឹងតថាគត ធ្វើនូវសេចក្ដីគោរពតថាគត រាប់អាននូវតថាគត បូជានូវតថាគត ដោយបដិបត្តិបូជា ជាបូជាយ៉ាងក្រៃលែង ។

**හន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ ភិក្ខវេ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ ឥទម្បច្ឆិមពុទ្ធវចនំ** ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងផ្ដាំនូវអ្នកទាំងឡាយឱ្យបានដឹងគ្រប់គ្នា នៃភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មានកិរិយាអស់ទៅ និងសាបសូន្យទៅជាធម្មតា ។ អ្នករាល់គ្នាចូរញាំងប្រយោជន៍ឱ្យដល់ព្រម ដោយអប្បមាទៈ គឺការមិនបណ្ដោតបណ្ដោយ ក្នុងធម៌វិន័យពាក្យប្រៀនប្រដៅ មានប្រមាណប៉ុណ្ណោះជាដើម នេះឈ្មោះថាបច្ឆិមពុទ្ធវចនៈ ជាពាក្យផ្ដាំពៅបំផុត របស់ព្រះពុទ្ធជាម្ចាស់នៃយើង ។

**ឧភិន្នមន្តរេ យំ វុត្តំ ឯតំ មជ្ឈិមពុទ្ធវចនំ** ពាក្យប្រដៅឯណា ដែលទ្រង់ត្រាស់ពោលជាចន្លោះនៃបឋមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈទាំងពីរនេះ ពាក្យប្រដៅនោះ ឈ្មោះថាមជ្ឈិមពុទ្ធវចនៈ គឺពាក្យប្រដៅជាកណ្ដាល របស់ព្រះពុទ្ធជាបរមគ្រូ( នៃយើង ) ។

ចប់បច្ឆិមពុទ្ធវចនៈ

# វន្ទាព្រះពុទ្ធ

(ឈរប្រណម្យដៃ បង្អោនខ្លួនទៅខាងមុខបន្តិច ពោលថា)

**ឱកាស វន្ទាមិ ភន្តេ (ភគវា), សព្វំ អបរាធំ ខមថ មេ ភន្តេ, មយា កតំ បុញ្ញំ សាមិនា អនុមោទិតព្វំ, សាមិនា កតំ បុញ្ញំ មយ្ហំ ទាតព្វំ, សាធុ សាធុ អនុមោទាមិ ៕**

(អង្គុយចុះហើយពោលថា)

**(ភគវា) សព្វំ អបរាធំ ខមថ មេ ភន្តេ ៕**

(ក្រាបរាបទៅនឹងកន្លែង ហើយពោលថា)

**ឱកាស ទ្វារត្តយេន កតំ (ភគវា) សព្វំ អបរាធំ ខមថ មេ ភន្តេ, ឱកាស ខមាមិ ភន្តេ, ខមាមិ ភន្តេ, ខមាមិ ភន្តេ ៕**

(ក្រោកឈរឡើងវិញដូចដើម ហើយពោលថា)

**វន្ទាមិ ភន្តេ (ភគវា) សព្វំ ៕ល៕ អនុមោទាមិ ៕**

(អង្គុយចុះ ក្រាបថ្វាយបង្គំ ៣ ដង)

# សមាទានបញ្ចសីល

ឧកាស មយំ(អហំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម(យាចាមិ) អនុគ្គហំ កត្វា សីសំ ទេថ នោ(មេ) ភន្តេ ។

ទុតិយម្បិ មយំ(អហំ) ភន្តេ ។ល។ .......... នោ(មេ) ភន្តេ ។

តតិយម្បិ មយំ(អហំ) ភន្តេ ។ល។ .......... នោ(មេ) ភន្តេ ។

(ម្នាក់ឯង ប្រើពាក្យក្នុងវង់ក្រចក)

# សមាទានឧបោសថសីល

ឧកាស មយំ(អហំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម(យាចាមិ) អនុគ្គហំ កត្វា សីសំ ទេថ នោ(មេ) ភន្តេ ។

ទុតិយម្បិ មយំ(អហំ) ភន្តេ ។ល។ ......... នោ(មេ) ភន្តេ ។

តតិយម្បិ មយំ(អហំ) ភន្តេ ។ល។ .......... នោ(មេ) ភន្តេ ។

# ធម្មទេសនាយាចនគាថា

ព្រហ្មា ច លោកាធិបតី សហម្បតី
កតញ្ជលី អនធិវរំ អាយាចថ
សន្តីធ សត្តាប្បរជក្ខជាតិកា
ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។
សទ្ធម្មភេរឹ វិនយញ្ច កាយំ
សុត្តញ្ច ពន្ធំ អភិធម្មចម្មំ
អាកោដយន្តោ ចតុសច្ចទណ្ឌំ
បញ្ចោធនេយ្យ បរិសាយ មជ្ឈេ ។

ឯវំ សហម្បតី ព្រហ្មា ភគវន្តំ អាយាចថ
តុណ្ហីភាវេន តំ ពុទ្ធោ ការុញ្ញេនាធិវាសយ ។
តម្ហា វុដ្ឋាយ បាទេន មិគទាយំ តតោ គតោ
បញ្ចវគ្គិយទយោ នេយ្យេ អមំ បាយេសិ ធម្មតោ ។
តតោ បភូតិ សម្ពុទ្ធោ អន្វូនា ធម្មទេសនំ
មាឃវស្សានិ ទេសេសិ សត្តានំ អត្ថសិទ្ធកំ ។
តេន សាធុ អយ្យោ ភន្តេ ទេសេតុ ធម្មទេសំ

សព្វាយិធ បរិយាយ អនុកម្បម្បិ កាតវេ ។

គ្រានោះសហម្បតី ព្រហ្មជាឥស្សរលោកា
ចូលគាល់ព្រះសាស្តា លើកហត្ថាសិរោរាប ។
ហើយពោលពាក្យទូលថា សូមករុណាស្តេចទ្រង់ជ្រាប
ដ្បិតសត្វអន់ទន់ទាប ទុព្វលភាពបាបក្រៃក្រាស់ ។
ទន្ទឹងព្រះធម៌ថ្លៃ ជានិស្ស័យបច្ច័យច្បាស់
ឥឡូវទ្រង់បានត្រាស់ ត្រេកអរណាស់ពុំកន្តើយ ។
សត្វខ្លះក្រាស់ដោយកាម មិនយល់តាមត្រៃលក្ខណ៍ឡើយ
ឥឡូវយល់ខ្លះហើយ ដោយអំណាចព្រះមានបុណ្យ
បើបានស្តាប់ទេសនា បញ្ញាក្លាខ្លាំងលើសមុន
សូមព្រះដ៏មានបុណ្យ ទ្រង់និមន្តត្រាស់ទេសនា ។
ប្រោសសត្វបំបាត់សោក ទាំងរាគរោគរូបតណ្ហា
ងងឹតប្រែជ្រះថ្លា កើតបញ្ញាភិយ្យោយល់ ។
ត្រៃលោកគោកត្រៃលក្ខណ៍ សង្សារចក្រវិលមិនដល់
អវិជ្ជាកប្ញសគល់ ជាបច្ច័យនៃសង្ខារ។
នាំសត្វឱ្យសោកសៅ លិចលង់នៅក្នុងសង្សារ
បញ្ចមារមោហន្ធការ រិតរុំហ៊ុមជុំជាប់នៅ។
ហេតុនោះសូមព្រះអង្គ ប្រោសស្រោចស្រង់ដាក់សំពៅ
ចម្លងសត្វឆ្ពោះទៅ កាន់ត្រើយត្រាណនិព្វាននាយ

ដូចកលប្រទីបធំ　　សាយត្រសុំភ្លឺព្រោងព្រាយ
បំភ្លឺសត្វទាំងឡាយ　　ឱ្យសប្បាយក្សាន្តភិរម្យ ។
ព្រះសទ្ធម្មជាស្គរជ័យ　　ព្រះវិន័យជារាងធំ
ព្រះសូត្រជាខ្សែរុំ　　ព្រះអភិធម្មជាស្បែកដាស។
អរិយសច្ចជាអន្លូង　　សម្រាប់ទូងឱ្យឮច្បាស់
សត្វលោកងោកងុយណាស់　　ឮស្គរដាស់ក្រោកឡើងបាន។
បរិស័ទបួនជំពូក　　ដូចផ្កាឈូកក្នុងជលដ្ឋាន
ខ្លះផុសចាំសូរ្យឆាន　　រះនឹងរីកដោយរស្មី។
ព្រះធម៌ជាសូរ្យសែង　　រះឡើងចែងចាំងរង្សី
បំភ្លឺលោកទាំងបី　　ឱ្យយល់ផ្លូវឋានសុខា ៕
សហម្បតីព្រហ្ម　　ឱនបង្គំអារាធនា
សម្តេចព្រះភគវា　　ដោយគាថាយ៉ាងនេះឯង ។
ព្រះពុទ្ធទ្រង់អនុកូល　　ព្រមទទួលនឹងសម្តែង
ដោយតុណ្ហីភាពថ្លែង　　តាមភាវៈគុណករុណា ។
ទើបក្រោកចាកទីនោះ　　ភក្ត្រាឆ្ពោះព្រៃមិគទា
យាងចេញចរលីលា　　ពីទីនោះដោយព្រះបាទ ។
ញុំាំងសត្វចូលពុទ្ធចក្រ　　មានបញ្ចវគ្គីយ៍ជាអាទិ៍
ឱ្យផឹកអម្រឹតជាត　　រសនិព្វានតាមធម្មតា។
ចាប់ដើមពីនោះឯង　　ទ្រង់សម្តែងធម៌ទេសនា
ធ្វើពុទ្ធក្រឹត្យា　　អស់វស្សាសែសិបប្រាំ ។

ពុំថយពុំបន្ធូរ ប្រយោជន៍យូរអង្វែងឆ្នាំ
សម្រេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រៃ ។
ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរក្រៃ
បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា ។
អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា
ឱ្យកើតមានប្រាជ្ញា ប្រាកដនាទីនេះហោង ៕

## បន្ទឹសព្វសាធុការពេលចប់ធម្មទេសនា

នៅពេលព្រះសង្ឃសម្តែងព្រះធម៌ទេសនាចប់ភ្លាម គឺពេលអង្គធម្មកថិកចប់ពាក្យថា ឯវំ អ្នកស្តាប់គប្បីបន្លឺសព្ទសាធុការសរសើរព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃព្រមៗ គ្នាថា

**សាធុ ពុទ្ធសុពោធិតា** !

*សាធុ ការត្រាស់ដឹងល្អប្រពៃនៃព្រះពុទ្ធ!*

**សាធុ សុធម្មតា** !

*សាធុ ភាវៈជាធម៌ល្អប្រពៃនៃព្រះធម៌!*

**សាធុ សង្ឃស្សុបដិបត្តិ** !

*សាធុ ការប្រតិបត្តិល្អប្រពៃនៃព្រះសង្ឃ!*

# ពុទ្ធិកសមាគមខ្មែរ ប្រចាំក្រុងសាន់ឌីអេហ្គោ

# វត្តខេមររតនារាម

The Cambodian Buddhist Society of San Diego, Inc.

3606 - 3616 47th Street, San Diego, CA 92105

**រៀបរៀងរួចជាស្ថាពរនៅថ្ងៃអាទិត្យ ១៥កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧**

**ត្រូវនឹងថ្ងៃទី២៩ ខែតុលា គ.ស. ២០២៣ ៕**

ទំនាក់ទំនងមកកាន់យើងតាមរយៈ

**Website** **Facebook** **YouTube**